**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ [illegible] ......សហវ.ប្រក

# ប្រកាស
# ស្តីពី
# ពន្ធប្រថាប់ត្រា

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

ប្រកាសនេះ មានគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធប្រថាប់ត្រា។

**ប្រការ២ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តលើ៖

១- ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ចលនទ្រព្យនិងអចលនទ្រព្យ ឬការដាក់ភាគហ៊ុនជាចលនទ្រព្យនិងអចលនទ្រព្យក្នុងក្រុមហ៊ុន។

២- ការផ្ទេរចំណែកណាមួយឬទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន ឬផលប្រយោជន៍ប្រហាក់ប្រហែល។

៣- កិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវាដែលប្រើប្រាស់ថវិការដ្ឋ។

៤- លិខិតមានលក្ខណៈគតិយុត្ត រួមមានលិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងលិខិតស្តីពីការបិទក្រុមហ៊ុន។

**ប្រការ៣ .-**

សម្រាប់គោលដៅនៃប្រកាសនេះ៖

១- វង្សញាតិ សំដៅដល់៖

ក- រវាងឪពុកម្ដាយបង្កើតនិងកូនបង្កើត។

ខ- រវាងប្តីនិងប្រពន្ធ។

គ- រវាងយាយតាបង្កើតនិងចៅបង្កើត។

ឃ-រវាងបងប្អូនបង្កើតនិងបងប្អូនបង្កើត។

ង- រវាងឪពុកម្ដាយក្មេកនិងកូនប្រសា។

ច- រវាងយាយតាក្មេកនិងចៅប្រសា។

២- ប្រទានកម្ម សំដៅដល់ ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យពីមនុស្សរស់ទៅឱ្យញាតិដោយមិនយកថ្លៃ។

៣- សន្តតិកម្ម សំដៅដល់ ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យពីមនុស្សស្លាប់ទៅឱ្យញាតិ តាមរយៈ៖

ក- បណ្តាំជាលាយលក្ខណ៍អក្សរ ករណីគ្មានទំនាស់ ឬ

ខ- បញ្ជាក់លើលិខិតយថាភូត ករណីគ្មានទំនាស់ ឬ

គ- សាលក្រម ឬសាលដីកាតុលាការ ករណីមានទំនាស់។

៤- តម្លៃចុះកិច្ចសន្យា សំដៅដល់ តម្លៃដែលមានចែងក្នុងកិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវាដែលប្រើប្រាស់ថវិការដ្ឋ។

៥- តម្លៃភាគហ៊ុន សំដៅដល់ តម្លៃនៃការផ្ទេរភាគហ៊ុនផ្អែកតាមតម្លៃទីផ្សារ។

៦- ភាគហ៊ុន សំដៅដល់ ចំណែកណាមួយឬទាំងស្រុងនៃភាគហ៊ុន ឬផលប្រយោជន៍ប្រហាក់ប្រហែល ឬការលក់អាជីវកម្មរបស់ក្រុមហ៊ុននីតិបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ និងសហគ្រាសឯកបុគ្គលដែលបានចុះបញ្ជីឬមិនបានចុះបញ្ជីនៅក្រសួងឬស្ថាប័នមានសមត្ថកិច្ច។

៧- អចលនទ្រព្យ សំដៅដល់ ដី ផ្ទះ អគារ និងសំណង់ផ្សេងៗ ទោះបីជាបានចុះបញ្ជីឬមិនបានចុះបញ្ជីដោយរដ្ឋបាលសុរិយោដី។

៨- ក្រុមហ៊ុនអចលនទ្រព្យ សំដៅដល់ ក្រុមហ៊ុនទាំងឡាយណាដែលកាន់កាប់អចលនទ្រព្យដោយផ្ទាល់ឬដោយប្រយោលដែលមានតម្លៃលើសពី ៥០ (ហាសិប) ភាគរយ នៃតម្លៃទ្រព្យសកម្មសរុបរបស់ក្រុមហ៊ុន។

៩- ចលនទ្រព្យ សំដៅដល់ មធ្យោបាយដឹកជញ្ជូនឬយានជំនិះគ្រប់ប្រភេទ ដូចជា កប៉ាល់ សាឡង់ ទូក កាណូត អូប័រ រថយន្ត ក្បាលរថយន្តសណ្ដោង រ៉ឺម៉កសណ្ដោង ស៊ីមីរ៉ឺម៉កសណ្ដោង ទោចក្រយានយន្ត ត្រីចក្រយានយន្ត ត្រាក់ទ័រ និងគ្រឿងយន្តប្រហាក់ប្រហែល។



ⴑ

១០- លិខិតមានលក្ខណៈគតិយុត្ត សំដៅដល់ លិខិតមានលក្ខណៈគតិយុត្តស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការបិទក្រុមហ៊ុនដែលបានចុះបញ្ជីនៅក្រសួងឬស្ថាប័នមានសមត្ថកិច្ច។

**ប្រការ៤ .-**

ពន្ធប្រថាប់ត្រាត្រូវកំណត់តាមអត្រាដូចខាងក្រោម៖

១- ៤ (បួន) ភាគរយ នៃតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យជាសំណង់ និង/ឬដី ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន ឬការផ្ទេរភាគហ៊ុន ឬផលប្រយោជន៍ប្រហាក់ប្រហែលរបស់ក្រុមហ៊ុនអចលនទ្រព្យ។

២- ៤ (បួន) ភាគរយ នៃតម្លៃចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ចលនទ្រព្យ ឬការដាក់ភាគហ៊ុនជាចលនទ្រព្យក្នុងក្រុមហ៊ុន។

៣- ០,១ (សូន្យក្បៀសមួយ) ភាគរយ នៃតម្លៃភាគហ៊ុនចំពោះការផ្ទេរចំណែកណាមួយឬទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន។

៤- ០,១ (សូន្យក្បៀសមួយ) ភាគរយ នៃតម្លៃចុះកិច្ចសន្យាចំពោះកិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវាដែលប្រើប្រាស់ថវិការដ្ឋ។

៥- ១ ០០០ ០០០ (មួយលាន) រៀល ចំពោះលិខិតមានលក្ខណៈគតិយុត្ត រួមមានលិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងលិខិតស្តីពីការបិទក្រុមហ៊ុន។

**ប្រការ៥ .-**

មូលដ្ឋានគិតពន្ធប្រថាប់ត្រាត្រូវបានកំណត់ដូចខាងក្រោម៖

១- តម្លៃចលនទ្រព្យនិងអចលនទ្រព្យត្រូវគិតតាមតម្លៃទីផ្សារនាពេលផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចកំណត់តម្លៃចលនទ្រព្យនិងអចលនទ្រព្យសម្រាប់ធ្វើជាមូលដ្ឋានគិតពន្ធនេះ។

២- តម្លៃភាគហ៊ុនឬផលប្រយោជន៍ប្រហាក់ប្រហែលត្រូវគិតតាមតម្លៃទីផ្សារនាពេលប្រតិបត្តិការផ្ទេរភាគហ៊ុនឬផលប្រយោជន៍ប្រហាក់ប្រហែលនោះកើតឡើង។

៣- តម្លៃចុះកិច្ចសន្យា ត្រូវគិតតាមតម្លៃក្នុងកិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវាដែលប្រើប្រាស់ថវិការដ្ឋ ដោយមិនរួមបញ្ចូលអាករលើតម្លៃបន្ថែម។

៤- លិខិតមានលក្ខណៈគតិយុត្តត្រូវកំណត់ ១ ០០០ ០០០ (មួយលាន) រៀល ចំពោះលិខិតមានលក្ខណៈគតិយុត្តនីមួយៗ។

**ប្រការ៦ .-**

ពន្ធប្រថាប់ត្រា ត្រូវបានលើកលែងនិងអនុគ្រោះដូចខាងក្រោម៖

១- ការលើកលែងពន្ធ៖ ពន្ធប្រថាប់ត្រា ត្រូវបានលើកលែងដូចខាងក្រោម៖

ក- ការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់ដីក្នុងលក្ខណៈសម្បទានពីរាជរដ្ឋាភិបាល សម្រាប់ជាប្រយោជន៍សេដ្ឋកិច្ច ឬសង្គមកិច្ច ពីដីឯកជនរបស់រដ្ឋដល់ជនក្រីក្រដែលខ្វះខាតដីសម្រាប់សង់លំនៅឋាន និង/ឬធ្វើកសិឧស្សាហកម្ម ឬកសិកម្មជាលក្ខណៈគ្រួសារ។

ខ- ការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ ក្នុងរង្វង់ញាតិ៖

- ការធ្វើសន្តតិកម្ម រវាងឪពុកម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ រវាងយាយតាបង្កើតនិងចៅបង្កើត និងរវាងឪពុកម្តាយនិងកូនបង្កើតនិងកូនប្រសាដែលជាសហព័ទ្ធរបស់កូនបង្កើតនោះ ដើម្បីជាទ្រព្យសម្បត្តិរួម



4

- ការធ្វើប្រទានកម្មលើកទី១ រវាងឪពុកម្ដាយបង្កើតនិងកូនបង្កើត រវាងប្ដីនិងប្រពន្ធ រវាងយាយតាបង្កើតនិងចៅបង្កើត រវាងឪពុកម្ដាយនិងកូនបង្កើតនិងកូនប្រសាដែលជាសហព័ទ្ធរបស់កូនបង្កើតនោះដើម្បីជាទ្រព្យសម្បត្តិរួម និងរវាងយាយតានិងចៅបង្កើតនិងចៅប្រសាដែលជាសហព័ទ្ធរបស់ចៅបង្កើតនោះដើម្បីជាទ្រព្យសម្បត្តិរួម។

គ- ការផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ត្រីចក្រយានយន្តនិងត្រាក់ទ័រគ្រប់ប្រភេទ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់ ១៥០ (មួយរយហាសិប) សេះ។

ឃ-ការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់ចលនទ្រព្យនិងអចលនទ្រព្យដែលត្រូវកត់ត្រាចុះក្នុងបញ្ជីសារពើភណ្ឌរបស់ស្ថាប័នរដ្ឋនានានៃព្រះរាជាណាចក្រកម្ពុជា។

ង- ការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់ចលនទ្រព្យនិងអចលនទ្រព្យរបស់បេសកកម្មការទូតឬកុងស៊ុលបរទេសអង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា។

ច- ការទិញចលនទ្រព្យធ្វើជាទំនិញដើម្បីលក់វិញរបស់សហគ្រាសនានាដែលបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធនិងបានបង់ពន្ធអាករប្រចាំខែនិងប្រចាំឆ្នាំ។ ដោយឡែក ការទិញចលនទ្រព្យដែលបានចុះបញ្ជីនៅស្ថាប័នសាធារណការនិងដឹកជញ្ជូន មិនត្រូវបានលើកលែងពន្ធប្រថាប់ត្រានេះទេ។

ឆ- ការទទួលបានសិទ្ធិកាន់កាប់ភាគហ៊ុនរបស់អ្នកវិនិយោគមូលបត្រ តាមរយៈការជួញដូរមូលបត្រក្នុងទីផ្សារដំបូងឬក្នុងទីផ្សារបន្ទាប់។ ការផ្ទេរភាគហ៊ុន ការទទួលសិទ្ធិកាន់កាប់ភាគហ៊ុន ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ការកែប្រែរចនាសម្ព័ន្ធភាគហ៊ុនិក ដូចជាការបំបែកភាគហ៊ុនរបស់ក្រុមហ៊ុនដែលមានបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈ ក្រុមហ៊ុនដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈនៅក្នុងទីផ្សារដំបូង ឬនៅក្នុងទីផ្សារបន្ទាប់ ឬក្រុមហ៊ុនដែលធ្វើអាជីវកម្មពាក់ព័ន្ធក្នុងវិស័យមូលបត្រ ទោះបីតម្រូវឱ្យមានការកែប្រែលក្ខន្តិកៈក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្មក៏ដោយ ការលើកលែងពន្ធប្រថាប់ត្រានេះ ត្រូវមានលិខិតបញ្ជាក់ពីនិយ័តករមូលបត្រកម្ពុជា។ ដោយឡែក ករណីក្រុមហ៊ុនមិនអាចធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈបាន ដោយអនុលោមតាមច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អ្នកទទួលសិទ្ធិកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុន ត្រូវជាប់ពន្ធប្រថាប់ត្រា និងត្រូវទូទាត់ពន្ធប្រថាប់ត្រានៃការផ្ទេរភាគហ៊ុនកន្លងមក ដោយអនុលោមតាមប្រកាសនេះ លើកលែងតែមានលិខិតបញ្ជាក់ដោយឡែកពីនិយ័តករមូលបត្រកម្ពុជាដោយផ្អែកលើមូលហេតុសមស្រប ដូចជាករណីប្រធានសក្ដិជាដើម។

២- ការអនុគ្រោះពន្ធ៖ ពន្ធប្រថាប់ត្រាត្រូវបានអនុគ្រោះ ដូចខាងក្រោម៖

ក- ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យរវាងឪពុកម្ដាយក្មេកនិងកូនប្រសា រវាងយាយតាក្មេកនិងចៅប្រសា និងរវាងបងប្អូនបង្កើតនិងបងប្អូនបង្កើត ត្រូវបានអនុញ្ញាតឱ្យដកចេញនូវមូលដ្ឋានគិតពន្ធប្រថាប់ត្រាចំនួន ២០០ ០០០ ០០០ (ពីររយលាន) រៀល ចំពោះការធ្វើសន្តតិកម្ម និងចំនួន ១០០ ០០០ ០០០ (មួយរយលាន) រៀល ចំពោះការធ្វើប្រទានកម្ម។

ខ- ការធ្វើប្រទានកម្មអចលនទ្រព្យដដែលចាប់ពីលើកទី២តទៅ រវាងឪពុកម្ដាយបង្កើតនិងកូនបង្កើត រវាងប្ដីនិងប្រពន្ធ រវាងយាយតាបង្កើតនិងចៅបង្កើត រវាងឪពុកម្ដាយនិងកូនបង្កើតនិងកូនប្រសាដែលជាសហព័ទ្ធរបស់កូនបង្កើតនោះដើម្បីជាទ្រព្យសម្បត្តិរួម និងរវាងយាយតានិងចៅបង្កើតនិងចៅប្រសាដែលជាសហព័ទ្ធរបស់ចៅបង្កើតនោះដើម្បីជាទ្រព្យសម្បត្តិរួម ត្រូវបានអនុញ្ញាតឱ្យដកចេញនូវមូលដ្ឋានគិតពន្ធប្រថាប់ត្រាចំនួន ១០០ ០០០ ០០០ (មួយរយលាន) រៀល។

៣- ការលើកលែងឬការអនុគ្រោះពន្ធប្រថាប់ត្រាក្នុងរង្វង់ញាតិដូចមានកំណត់ក្នុងប្រកាសនេះ តម្រូវឱ្យមានឯកសារនិងភស្តុតាងបញ្ជាក់ទំនាក់ទំនងអំពីញាតិ ដូចជា សៀវភៅគ្រួសារ សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និង/ឬឯកសារដទៃទៀតអាចបញ្ជាក់ទំនាក់ទំនងរវាងបុគ្គលដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការ៣ នៃប្រកាសនេះ។

៤- ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យដែលត្រូវបានលើកលែងពន្ធ ឬការអនុគ្រោះពន្ធប្រថាប់ត្រា ទោះបីជាមានប្រាក់ពន្ធស្មើ ០ (សូន្យ) រៀល ក៏ត្រូវបំពេញបែបបទនិងនីតិវិធីនៅរដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងប្រការ៨ នៃប្រកាសនេះ ដើម្បីចុះបញ្ជីនិងកត់ត្រាទិន្នន័យនូវរាល់ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យទាំងនោះ។

**ប្រការ៧ .-**

ពន្ធប្រថាប់ត្រាត្រូវអនុវត្តចំពោះ៖

១- អ្នកទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់ចលនទ្រព្យនិងអចលនទ្រព្យ។

២- អ្នកទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់ភាគហ៊ុន។

៣- អ្នកទទួលបានកិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវាដែលប្រើប្រាស់ថវិការដ្ឋ។

៤- អ្នកទទួលសិទ្ធិលើលិខិតមានលក្ខណៈគតិយុត្ត។

**ប្រការ៨ .-**

អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ច ដូចខាងក្រោម៖

១- ដាក់លិខិតប្រកាសសារពើពន្ធនិងបង់ប្រាក់ពន្ធឱ្យបានចប់សព្វគ្រប់ក្នុងរយៈពេល ៣ខែ ចំពោះ៖

ក- អចលនទ្រព្យដែលបានចុះបញ្ជី (មានបណ្ណកម្មសិទ្ធិ) បន្ទាប់ពីកាលបរិច្ឆេទនៃដីកាបញ្ជូនសំណុំឯកសារផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យនេះ។

ខ- អចលនទ្រព្យដែលមិនទាន់ចុះបញ្ជី (គ្មានបណ្ណកម្មសិទ្ធិ) បន្ទាប់ពីកាលបរិច្ឆេទនៃដីកាបញ្ជូនសំណុំឯកសារផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យរបស់រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ ឬរដ្ឋបាលឃុំ/សង្កាត់ ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យនេះ។

គ- ចលនទ្រព្យ បន្ទាប់ពីថ្ងៃចុះហត្ថលេខារបស់អ្នកទទួលសិទ្ធិលើសំណុំឯកសារ "ពាក្យសុំផ្ទេរកម្មសិទ្ធិយានយន្ត" របស់មន្ទីរសោធារណការនិងដឹកជញ្ជូនរាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងការផ្ទេរកម្មសិទ្ធិនេះ។

ឃ-ភាគហ៊ុន បន្ទាប់ពីប្រតិបត្តិការផ្ទេរភាគហ៊ុនកើតឡើង ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងការផ្ទេរភាគហ៊ុននេះ។

ង- កិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវា បន្ទាប់ពីកាលបរិច្ឆេទនៃកិច្ចសន្យាដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងកិច្ចសន្យានេះ។

ច- លិខិតមានលក្ខណៈគតិយុត្ត បន្ទាប់ពីការសម្រេចរបស់ក្រសួង ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ច ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងលិខិតទាំងនេះ។

២- ការផ្ទេរ ឬប្រតិបត្តិការទិញលក់ដូចខាងក្រោម ពុំតម្រូវឱ្យមកប្រថាប់ត្រានៅរដ្ឋបាលសារពើពន្ធនោះទេ៖

ក- ការផ្ទេរឬការទទួលសិទ្ធិកាន់កាប់ភាគហ៊ុនពាក់ព័ន្ធនឹងវិស័យមូលបត្រដូចមានចែងក្នុងវាក្យខណ្ឌ ឆ នៃកថាខណ្ឌទី១ នៃប្រការ៦ នៃប្រកាសនេះ។

ខ- ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ទោចក្រយានយន្ត ត្រីចក្រយានយន្តនិងត្រាក់ទ័រគ្រប់ប្រភេទ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់ ១៥០ (មួយរយហាសិប) សេះ ដូចមានចែងក្នុងវាក្យខណ្ឌ គ នៃកថាខណ្ឌទី១ នៃប្រការ៦ នៃប្រកាសនេះ។

គ- ការទិញចលនទ្រព្យ ដើម្បីធ្វើជាទំនិញដើម្បីលក់វិញរបស់សហគ្រាសនានា ដែលបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ និងបានបង់ពន្ធអាករប្រចាំខែ និងប្រចាំឆ្នាំ ដូចមានចែងក្នុងវាក្យខណ្ឌ ច នៃកថាខណ្ឌទី១ នៃប្រការ៦ នៃប្រកាសនេះ។

**ប្រការ៩ .-**

ប្រសិនបើអ្នកទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់ចលនទ្រព្យនិងអចលនទ្រព្យណាមួយដូចមានចែងក្នុងប្រការ៧ នៃប្រកាសនេះ មិនបានបង់ប្រាក់ពន្ធប្រថាប់ត្រាតាមច្បាប់នោះទេ៖

១- រដ្ឋបាលសុរិយោដីមិនត្រូវចេញឬផ្ទេរវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬបណ្ណសម្គាល់សិទ្ធិអចលនវត្ថុ ឬបណ្ណប្រហាក់ប្រហែលថ្មីនោះទេ។

២- អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ មិនត្រូវបញ្ជាក់លើការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យ។

៣- ស្ថាប័នសាធារណការនិងដឹកជញ្ជូន ឬអាជ្ញាធរមានសមត្ថកិច្ចមិនត្រូវចេញបណ្ណសម្គាល់ថ្មី ចំពោះការផ្ទេរកម្មសិទ្ធិលើចលនទ្រព្យគ្រប់ប្រភេទ វៀរលែងតែទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងជលយានយន្តដែលមានកម្លាំងដល់ ១៥០ (មួយរយហាសិប) សេះ។

**ប្រការ១០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១ .-**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ១១ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ